ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ០៩៥ សជណ/គ.ជ.អ.ប

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣

## គោរពជូន

**អភិបាលខេត្តបាត់ដំបង កំពង់ចាម កណ្តាល កំពង់ស្ពឺ កំពង់ធំ មណ្ឌលគិរី ព្រៃវែង រតនគិរី ពោធិ៍សាត់ ព្រះវិហារ ក្រចេះ សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង ប៉ៃលិន និងឧត្តរមានជ័យ**

<u>កម្មវត្ថុ</u> ៖ ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គមគាំទ្រដោយកម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វ ។

<u>យោង</u> ៖ - សេចក្តីជូនដំណឹងលេខ២២០ សជណ/គ.ជ.អ.ប ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ ស្តីពីក្របខ័ណ្ឌសកម្មភាពសេវាសង្គមនៅថ្នាក់ក្រោមជាតិ

- សេចក្តីណែនាំលេខ១៦៤៦ អ.រតន ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ស្តីពីការកំណត់លិខិតយុត្តិការចំណាយមូលនិធិគាំទ្រការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា ទារក មត្តេយ្យសហគមន៍ ទឹកស្អាតនិងអនាម័យ សមភាពយេនឌ័រ កិច្ចការពារកុមារ ការចុះបញ្ជីអត្រានុកូលដ្ឋាន ការលើកកម្ពស់ ការថែទាំនិងអភិវឌ្ឍន៍កុមារតូច និងការរៀបចំនិងការដោះស្រាយគ្រោះមហន្តរាយនៅឃុំ សង្កាត់
- សេចក្តីជូនដំណឹងលេខ៧៥៦ ស.ណ/គ.ជ.អ.ប ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីការបន្តការប្រើប្រាស់មូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គមដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារសម្រាប់សកម្មភាពសេវាសង្គម
- សេចក្តីជូនដំណឹងលេខ០៨៤ សជណ/គ.ជ.អ.ប ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ស្តីពីការគាំទ្រមូលនិធិឃុំបន្ថែមសម្រាប់លើកកម្ពស់ការផ្តល់សេវាសង្គមក្នុងឆ្នាំ២០១៣ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ក្នុងឆ្នាំ២០១១-២០១២ ការគាំទ្រមូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គមរបស់កម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វ គឺមានការកំណត់រួចជាស្រេចអំពីប្រភេទសកម្មភាព និងថវិកាដែលត្រូវប្រើប្រាស់ ។ ប៉ុន្តែក្នុងឆ្នាំ២០១៣នេះ កម្មវិធីសិទ្ធិកុមារបានផ្តល់ការគាំទ្រដល់មូលនិធិឃុំ សង្កាត់ ជាកញ្ចប់រួមសម្រាប់ឃុំនីមួយៗ (សេចក្តីជូនដំណឹងលេខ០៨៤ខាងលើ) ដើម្បីគាំទ្រសកម្មភាពនានាពាក់ព័ន្ធនឹងសេវាសង្គម ផ្អែកតាមតម្រូវការជាក់ស្តែង និងជាអាទិភាពរបស់ឃុំនីមួយៗ ។

ពាក់ព័ន្ធនឹងការប្រើប្រាស់មូលនិធិឃុំ គិតត្រឹមចុងខែធ្នូ២០១២ សមតុល្យនៃការចំណាយមូលនិធិឃុំដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារក្នុងឆ្នាំ២០១១-២០១២ មានចំនួន១.៧១៩.៥២០.៤៨៥រៀល ។ ដូច្នេះ ក្នុងឆ្នាំ២០១៣នេះ ឃុំដែលស្ថិតក្នុងតំបន់គោលដៅគាំទ្ររបស់កម្មវិធីសិទ្ធិកុមារអាចមានមូលនិធិផ្នែកសេវាសង្គមពីរប្រភេទ គឺមូលនិធិដែលសល់ពីឆ្នាំ២០១១-២០១២ និងមូលនិធិសម្រាប់ឆ្នាំ២០១៣ ។ អាស្រ័យហេតុនេះ ដើម្បីប្រើប្រាស់មូលនិធិឃុំផ្នែកសេវាសង្គមប្រកបដោយប្រសិទ្ធភាព និងតម្លាភាព លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំដូចមានរៀបរាប់ខាងក្រោម ។

១. ឃុំ សង្កាត់ដែលពុំទទួលបានការគាំទ្រពីកម្មវិធីសិទ្ធិកុមារឆ្នាំ២០១៣

ចំពោះឃុំ សង្កាត់នានាដែលពុំទទួលបានការគាំមូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គមពីកម្មវិធីសិទ្ធិកុមារក្នុងឆ្នាំ ២០១៣ ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គមដែលសល់ពីឆ្នាំ២០១១-២០១២ ត្រូវអនុវត្តដូចខាងក្រោម ៖

- បន្តគាំទ្រសកម្មភាពនានាផ្នែកសេវាសង្គមដែលពុំទាន់បានអនុវត្តចប់ក្នុងឆ្នាំ២០១២ (បើមាន) ប្រសិនបើសកម្មភាពទាំងនោះនៅតែជាអាទិភាពក្នុងឆ្នាំ២០១៣ និង
- ប្រើប្រាស់ជាទូទៅសម្រាប់គាំទ្រសកម្មភាពនានាពាក់ព័ន្ធនឹងសេវាសង្គម ផ្អែកតាមតម្រូវការជាក់ស្តែង និងជាអាទិភាពរបស់ឃុំនីមួយៗ។

២. ឃុំដែលទទួលបានការគាំទ្រពីកម្មវិធីសិទ្ធិកុមារឆ្នាំ២០១៣

ចំពោះឃុំនានាដែលទទួលបានការគាំមូលនិធិផ្នែកសេវាសង្គមពីកម្មវិធីសិទ្ធិកុមារក្នុងឆ្នាំ២០១៣ មូលនិធិសរុបផ្នែកសេវាសង្គមក្នុងឆ្នាំ២០១៣ រួមមានមូលនិធិដែលសល់ពីឆ្នាំ២០១១-២០១២ និងមូលនិធិវិភាជន៍ក្នុងឆ្នាំ២០១៣ ហើយការប្រើប្រាស់មូលនិធិនេះត្រូវអនុវត្តដូចខាងក្រោម ៖

- ចំពោះមូលនិធិដែលជាសមតុល្យពីឆ្នាំ២០១១-២០១២ ត្រូវបន្តប្រើប្រាស់សម្រាប់សកម្មភាពនានាផ្នែកសេវាសង្គមដែលពុំទាន់បានអនុវត្តចប់ក្នុងឆ្នាំ២០១២ (បើមាន) ប្រសិនបើសកម្មភាពទាំងនោះនៅតែជាអាទិភាពក្នុងឆ្នាំ២០១៣
- មូលនិធិដែលសល់ពីគ្រោងចំណាយសម្រាប់សកម្មភាពដូចបានរៀបរាប់ខាងលើ រួមនឹងមូលនិធិផ្នែកសេវាសង្គមឆ្នាំ២០១៣ ត្រូវប្រើប្រាស់ជាទូទៅសម្រាប់គាំទ្រសកម្មភាពនានាពាក់ព័ន្ធនឹងសេវាសង្គម ផ្អែកតាមតម្រូវការជាក់ស្តែង និងជាអាទិភាពរបស់ឃុំនីមួយៗ។

ការរៀបចំ និងការអនុវត្តសកម្មភាពនានាផ្នែកសេវាសង្គម ត្រូវអនុវត្តតាមដំណើរការ និងនីតិវិធីដែលបានអនុវត្តកន្លងមក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងណែនាំដល់មេឃុំនៃឃុំគោលដៅក្នុងការរៀបចំថវិកាឆ្នាំ២០១៣របស់ខ្លួនឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ន. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

**ចម្លងជូន ៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ១៧ខេត្ត
- រតនាគារ១៧ខេត្ត
- ឯកសារ-កាលប្បវត្តិ